ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋបាលជលផល

# សៀវភៅមេរៀនស្តីពី
# សហគ្រប់គ្រងធនធានជលផល

## សៀវភៅទី៤ : ការពង្រឹងសមត្ថភាពខណ្ឌរដ្ឋបាលជលផល



ខែសីហា ឆ្នាំ២០១៨

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

# សៀវភៅមេរៀនស្តីពីសហគ្រប់គ្រងធនធានជលផល

## សៀវភៅទី៤ : ការពង្រឹងសមត្ថភាពខណ្ឌរដ្ឋបាលជលផល

រៀបចំដោយ
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
រដ្ឋបាលជលផល

**សេចក្តីថ្លែងអំណរគុណ**

រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចងក្រងសៀវភៅមេរៀននេះ ក្រោមការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោក។

សៀវភៅមេរៀនទាំងនេះគឺជាសមិទ្ធិផលរបស់គម្រោងការគ្រប់គ្រងធនធានទឹកចម្រុះ ទន្លេមេគង្គ - ដំណាក់កាលទី ៣ (M-IWRMP-III) "ការគាំទ្រការគ្រប់គ្រងធនធានជលផលនៅភូមិភាគឦសាននៃប្រទេសកម្ពុជា" ដែលអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប។

**ចងក្រងដោយ**

រូបឹត៍ ផមរ៉យែ អេរិក បារ៉ាន ទូច គឹមធាន សូខន សារុទ្ធ លី វុទ្ធី ទុយ សមរាំ ឈួន ឡា សូ វត្ថថាវី ផា ស្រួយ ប៊ុន រ៉ាស៊ី ទូច ប៊ុនថង ឆេង ផែន និង អេង ជាសាន។

**ជំនួយការ**

ស៊ឹម ថាវរី អ៊ូ សារី ធៀង សីហា ភូ សុខ ទិត្យ ពុទ្ធារ័ត្ន ប៉ុស ចាន់ណារ៉ា កែន ឡៃហ៊ាង ភាជន៍ ឧស្សាហ៍ ទឹម សណ្តាន និងគូររូបដោយ ហេង សន្ធា។

សូមថ្លែងអំណរគុណដល់អ្នកជំនាញការ និងទីប្រឹក្សានៃធនាគារពិភពលោកដែលបានផ្តល់នូវមតិ និងកែលម្អ។

**ISBN-13: 978-9924-9278-0-8**

**គុណកថាបង្អែក**

រដ្ឋបាលជលផល (២០១៨). សៀវភៅបណ្តុះបណ្តាលស្តីពីការសហការគ្រប់គ្រងជលផល សៀវភៅទី៤: ការពង្រឹងសមត្ថភាពខណ្ឌរដ្ឋបាលជលផល។ រដ្ឋបាលជលផល និងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប រាជធានីភ្នំពេញ ប្រទេសកម្ពុជា ៣៣ទំព័រ។

**អាសយដ្ឋានទំនាក់ទំនង**

រដ្ឋបាលជលផល

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

អាគារលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា

គេហទំព័រ ifredi-cambodia.org

**© រដ្ឋបាលជលផល (២០១៨)**

រក្សាសិទ្ធិ។ ការបោះពុម្ពឡើងវិញទាំងស្រុង ឬផ្នែកណាមួយសម្រាប់គោលបំណងអប់រំ ឬមិនរកប្រាក់ចំណេញ ដោយមិនចាំបាច់សុំការអនុញ្ញាតពីម្ចាស់ដើម និងគ្រាន់តែថ្លែងអំណរគុណដល់ប្រភពដើមត្រូវបានអនុញ្ញាត។ រាល់ការបោះពុម្ពការចម្លង ឬចែកចាយសម្រាប់ធ្វើពាណិជ្ជកម្មត្រូវសុំការអនុញ្ញាតពីរដ្ឋបាលជលផល។

គ្រប់មតិ និងគំនិតទាំងអស់ជាទស្សនៈរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីរដ្ឋបាលជលផល ដៃគូ ស្ថាប័នគាំទ្រគម្រោង និងការបោះពុម្ពសៀវភៅនេះ។

# មាតិកា


១. តើសហគ្រប់គ្រងធនធានជលផលមានន័យដូចម្តេច? ..... ១
២. គោលការណ៍នៃការគ្រប់គ្រងធនធានជលផលផ្តោតលើប្រពន្ធ័អេកូឡូស៊ី ..... ២
៣. តើសហគមន៍នេសាទមានន័យដូចម្តេច? ..... ៤
៤. ការបង្កើតសហគមន៍នេសាទ ..... ៥
៤.១ ជំហានទី១៖ ការបង្កើតក្រុមស្ថាបនិក និងសំណើបង្កើតសហគមន៍នេសាទ ..... ៦
៤.២ ជំហានទី១ក៖ ការផ្សព្វផ្សាយបំផុសការយល់ដឹង តាមរយៈការអប់រំ អភិវឌ្ឍន៍សមត្ថភាព និងការប្រាស្រ័យទាក់ទង ..... ៧
៤.៣ ជំហានទី២៖ ការសិក្សាលទ្ធភាពបង្កើតសហគមន៍នេសាទ ..... ៨
៤.៤ ជំហានទី៣៖ ការផ្សព្វផ្សាយ និងចុះឈ្មោះសមាជិកសហគមន៍នេសាទ ..... ៩
៤.៥ ជំហានទី៤៖ ការរៀបចំទស្សនៈវិស័យ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ..... ១១
៤.៦ ជំហានទី៥៖ ការធ្វើសន្និបាតលើកដំបូងជ្រើសរើសគណៈកម្មការសហគមន៍នេសាទ ..... ១២
៤.៧ តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ ..... ១៣
៤.៨ ជំហានទី៦៖ ការកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍ ..... ១៥
៤.៩ ជំហានទី៧៖ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ..... ១៦
៤.១០ ជំហានទី៨៖ ការចុះបញ្ជី និងការទទួលស្គាល់សហគមន៍នេសាទ ..... ១៨
៤.១១ ជំហានទី៩៖ ការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ១៩
៤.១២ សកម្មភាពយេនឌ័រនៅក្នុងការរៀបចំផែនការ ..... ២២
៤.១៣ សេចក្តីសង្ខេប ..... ២៣
៥. ការគ្រប់គ្រងវិវាទ ..... ២៥
៦. ការគោរពច្បាប់ និងការពង្រឹងការអនុវត្តច្បាប់ ..... ២៧
៧. បណ្តាញ ..... ២៨
៨. តួនាទី និងភារកិច្ចរបស់ខណ្ឌរដ្ឋបាលជលផលចំពោះសហគមន៍នេសាទ ..... ២៩
៩. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ..... ៣១
១០. ជំនួយបច្ចេកទេសទៅដល់សហគមន៍នេសាទ ..... ៣២
១១. របាយការណ៍សកម្មភាព ..... ៣៣

## ១. តើសហគ្រប់គ្រងធនធានជលផលមានន័យដូចម្តេច?

សហគ្រប់គ្រង សំដៅដល់ភាពជាដៃគូរវាងសហគមន៍នេសាទ ស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត (ដូចជា៖ អ្នកលក់ត្រី អ្នកជំនួញ អង្គការមិនមែនរដ្ឋាភិបាល ។ល។) និងការបែងចែកសិទ្ធិរួមទាំងការទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានជលផល។

សហគមន៍នេសាទនៅប្រទេសកម្ពុជា គឺអនុវត្តតាមគោលការណ៍សហគ្រប់គ្រង។ ស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាលគឺជាដៃគូជាមួយនឹងសហគមន៍នេសាទក្នុងការគ្រប់គ្រងធនធានជលផល។

តាមរយៈកិច្ចពិគ្រោះយោបល់ និងការចរចា រដ្ឋបាលជលផល និងសហគមន៍នេសាទត្រូវបង្កើតកិច្ចព្រមព្រៀងដូចជា៖ កន្លែងនេសាទសហគមន៍ តួនាទី និងភារកិច្ចរបស់ភាគីពាក់ព័ន្ធ និងសិទ្ធិក្នុងការគ្រប់គ្រងធនធានជលផល។

សហគ្រប់គ្រងធនធានជលផលរួមមាន៖

- សមាជិកភាពប្រកបដោយសមធម៌៖ យុត្តិធម៌ ស្មើភាព និងបើកទូលាយចំពោះប្រជាពលរដ្ឋទូទៅ (ស្ត្រី និងជនជាតិដើមភាគតិចត្រូវបានលើកទឹកចិត្តឱ្យចូលជាសមាជិកសហគមន៍នេសាទ)
- រួបរួមគ្នា និងសហប្រតិបត្តិការ៖ ធ្វើការជាមួយអ្នកណាម្នាក់ ផលិតអ្វីមួយ
- បែងចែកសិទ្ធិអំណាច (ការទទួលខុសត្រូវ និងសិទ្ធិអំណាច)៖ ទទួលខុសត្រូវរួមគ្នាលើការសម្រេចចិត្ត
- មានគោលដៅច្បាស់លាស់
- កិច្ចព្រមព្រៀង៖ ការរៀបចំរវាងភាគីពាក់ព័ន្ធ ចំពោះសកម្មភាពជាក់លាក់។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

វិធីសាស្ត្រថ្មីនៃការគ្រប់គ្រងធនធានជលផល គឺការទទួលស្គាល់នូវការចូលរួមពីប្រជានេសាទ ការទទួលស្គាល់ភាពជាម្ចាស់ និងសម្រេចចិត្តរួមគ្នា។

កាលពីមុន ការសម្រេចចិត្តនានាទាក់ទងនឹងការគ្រប់គ្រងធនធានជលផល មានលក្ខណៈប្រមូលផ្តុំ និងស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល (រដ្ឋបាលជលផលធ្វើការសម្រេចចិត្ត អនុវត្តសកម្មភាព ត្រួតពិនិត្យការងារ និងដាក់ពិន័យជាដើម)។ ចំពោះសហគ្រប់គ្រងធនធានជលផលវិញ ការសម្រេចចិត្តលើការគ្រប់គ្រងធនធានជលផល និងការទទួលខុសត្រូវ ត្រូវបានបែងចែករវាងសហគមន៍នេសាទ និងស្ថាប័នរាជរដ្ឋាភិបាល។

## ២. គោលការណ៍នៃការគ្រប់គ្រងធនធានជលផលផ្តោតលើប្រព័ន្ធអេកូឡូស៊ី

វិធីសាស្ត្រគ្រប់គ្រងដោយផ្តោតលើប្រព័ន្ធអេកូឡូស៊ី គឺជាវិធីសាស្ត្រមួយដែលមានតុល្យភាពរវាងសមាសធាតុចំនួនបី គឺបរិស្ថាន សង្គម(សុខុមាលភាព) និងអភិបាលកិច្ច។

- បរិស្ថានល្អ៖ មានពូជត្រីគ្រប់ប្រភេទ ផលត្រីសម្បូរ មិនធ្វើឱ្យខូចខាតជម្រកត្រី និងទឹកមានគុណភាព
- សង្គម(សុខុមាលភាព)៖ ប្រជាពលរដ្ឋមានស្តង់ដាររស់នៅល្អ (ប្រាក់ចំណូលសមរម្យ) សុវត្ថិភាពស្បៀង ទំនាក់ទំនងសង្គមមានភាពប្រសើរឡើង និងធានាសុវត្ថិភាព
- អភិបាលកិច្ចល្អ៖ សំដៅដល់ការចូលរួម សិទ្ធិជាផ្លូវការ សមធម៌ យន្តការរៀបចំផែនការ និងការអនុវត្ត ការគោរព និងពង្រឹងការអនុវត្តន៍ច្បាប់។

វាជាវិធីសាស្ត្រដែលគិតគូរទៅលើធាតុសំខាន់ៗនៅក្នុងប្រព័ន្ធអេកូឡូស៊ី ហើយគិតគូរពីផលប្រយោជន៍សេដ្ឋកិច្ចសង្គមបានមកតាមរយៈការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។




### គន្លឹះសម្រាប់អ្នកសម្របសម្រួល

គោលការណ៍ខាងលើ ឆ្លុះបញ្ចាំងអំពីវិធីសាស្ត្រផ្តោតលើប្រព័ន្ធអេកូឡូស៊ី ចំពោះការគ្រប់គ្រងធនធានជលផល។

ការគ្រប់គ្រងធនធានជលផលដែលមានស្រាប់ ហាក់ដូចជាមិនបានគ្របដណ្តប់ ដល់ការគំរាមកំហែង និងបញ្ហាដែលកើតមានក្នុងវិស័យជលផលទេ (ដូចជាការបាត់បង់ជម្រកត្រីពងកូន និងការបែងចែងផលប្រយោជន៍ដោយសមធម៌)។ ដូចនេះទាមទារឱ្យមានវិធីសាស្ត្រទូលំទូលាយ និងមានការចូលរួមជាងនេះ។

- វិធីសាស្ត្រផ្តោតលើប្រព័ន្ធអេកូឡូស៊ី (មានលក្ខណៈគ្រប់ជ្រុងជ្រោយ ភាពចម្រុះ និងការគ្រប់គ្រងដោយមានការចូលរួម) ដែលផ្តោតលើសមាសធាតុទាំង៣ និងផលប្រយោជន៍សេដ្ឋកិច្ចសង្គម តាមរយៈ ការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។ ប្រព័ន្ធអេកូឡូស៊ីកំណត់នូវតុល្យភាពរវាង ១) បរិស្ថានល្អ ២) សុខុមាលភាពប្រជាពលរដ្ឋ និង ៣) អភិបាលកិច្ចល្អសម្រាប់មនុស្សជំនាន់ក្រោយ
- ការគ្រប់គ្រងធនធានជលផល ផ្តោតលើប្រព័ន្ធអេកូឡូស៊ី ផ្តល់នូវទស្សនៈវិស័យទូលំទូលាយជាងទស្សនទានស្តីពីជលផល (រួមមានបរិស្ថាន និងជម្រកត្រីល្អ និងកែលម្អសុខុមាលភាពរបស់ប្រជាពលរដ្ឋ)
- ការគ្រប់គ្រងធនធានជលផល ផ្តោតលើប្រព័ន្ធអេកូឡូស៊ី ផ្តោតលើទិដ្ឋភាពធំៗ - ដែលទទួលស្គាល់ថា ធនធានជលផល ជាចំណែកមួយនៃប្រព័ន្ធអេកូឡូស៊ី ដែលត្រីរស់នៅបាន ប្រជាពលរដ្ឋក៏ទទួលបានផលប្រយោជន៍ពីការនេសាទ លក់ដូរ និងបរិភោគផងដែរ។

## ៣. តើសហគមន៍នេសាទមានន័យដូចម្តេច?

សហគមន៍នេសាទគឺជា៖

- ក្រុមរូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ
- ចូលរួមជាសមាជិកសហគមន៍នេសាទដោយស្ម័គ្រចិត្ត រស់នៅក្នុង ឬក្បែរដែននេសាទ
- មានគំនិតផ្តួចផ្តើម កែលម្អគុណភាពជីវិតដោយប្រើប្រាស់ និងកែច្នៃធនធានជលផលប្រកប ដោយនិរន្តរភាព។

សហគមន៍នេសាទតំណាងឱ្យប្រជាពលរដ្ឋកម្ពុជាក្នុងភាពជាដៃគូជាមួយនឹងស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល ដែលមានរដ្ឋបាលជលផលជាតំណាង។ រដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវការសហការរៀបចំសហគមន៍នេសាទ។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទលេខ.២៥ អនក្រ ជំពូក២ មាត្រា៦ ចែងថា៖ ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទ នៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ដើម្បីរួមចំណែកគ្រប់គ្រង អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផលប្រកប ដោយនិរន្តរភាព ។

លិខិតបទដ្ឋានគតិយុត្តទាំងអស់ (រួមមាន៖ ច្បាប់ជលផល ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសស្តីពីសហគមន៍នេសាទ) បានផ្តល់ការគាំទ្រផ្នែកច្បាប់សម្រាប់សហគ្រប់គ្រងធនធានជលផល នៅក្នុងប្រទេសកម្ពុជា និងបង្កើតភាពជាដៃគូរវាងប្រជានេសាទ និងស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាលក្នុងការចែករំលែកសិទ្ធិអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រងសហគមន៍នេសាទ។

# ៤. ការបង្កើតសហគមន៍នេសាទ

ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទបានកំណត់**ជំហានទាំង៩** រួមមាន៖

- ជំហានទី១៖ ការបង្កើតក្រុមស្ថាបនិក និងដាក់ពាក្យស្នើសុំបង្កើតសហគមន៍នេសាទ
- ជំហានទី២៖ ការសិក្សាលទ្ធភាពបង្កើតសហគមន៍នេសាទ
- ជំហានទី៣៖ ការចុះឈ្មោះសមាជិកសហគមន៍
- ជំហានទី៤៖ ការរៀបចំទស្សនៈវិស័យ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- ជំហានទី៥៖ ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- ជំហានទី៦៖ ការរៀបចំផែនទីកន្លែងនេសាទសហគមន៍
- ជំហានទី៧៖ ការរៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ជំហានទី៨៖ ការចុះបញ្ជីសហគមន៍នេសាទ
- ជំហានទី៩៖ ការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។



## ៤.១ ជំហានទី១៖ ការបង្កើតក្រុមស្ថាបនិក និងសំណើបង្កើតសហគមន៍នេសាទ

សហគមន៍មូលដ្ឋាន ដែលចង់បង្កើតសហគមន៍នេសាទ ត្រូវបង្កើតក្រុមស្ថាបនិកជាមុន។ ក្រុមស្ត្រី ជនជាតិដើមភាគតិច ក្រុមភាគតិច គួរត្រូវបានបញ្ចូលក្នុងក្រុមស្ថាបនិក។ ក្រុមស្ថាបនិកផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋក្នុងភូមិ អំពីផលប្រយោជន៍នៃការបង្កើតសហគមន៍នេសាទ បន្ទាប់មកដាក់សំណើទៅខណ្ឌរដ្ឋបាលជលផល ដើម្បីជួយសម្របសម្រួលបង្កើតសហគមន៍។



### គន្លឹះសម្រាប់អ្នកសម្របសម្រួល

សមាជិកក្រុមស្ថាបនិកត្រូវដាក់សំណើជាលាយល័ក្ខអក្សរទៅខណ្ឌរដ្ឋបាលជលផល តាមរយៈមេឃុំ ចៅសង្កាត់ សង្កាត់ជលផល និងផ្នែកជលផល ដោយមានភ្ជាប់ជាមួយនូវផែនទីដែននេសាទ (គូរដោយដៃ) បញ្ជាក់ទីតាំង (ប្រការ៣)។

## ៤.២ ជំហានទី១ក៖ ការផ្សព្វផ្សាយបំផុសការយល់ដឹង តាមរយៈការអប់រំ អភិវឌ្ឍន៍សមត្ថភាព និងការប្រាស្រ័យទាក់ទង

មុននឹងរៀបចំឯកសារស្នើសុំបង្កើតសហគមន៍នេសាទ ក្រុមស្ថាបនិកត្រូវផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋអំពីផលប្រយោជន៍នៃការបង្កើតសហគមន៍នេសាទ។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ ជំពូកទី២ ប្រការ៧ បានកំណត់ថា៖ *"សមាជិកក្រុមសម្របសម្រួល និងសមាជិកក្រុមស្ថាបនិកត្រូវរៀបចំផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋក្នុងមូលដ្ឋាន អំពីសារប្រយោជន៍នៃការបង្កើតសហគមន៍នេសាទ ដើម្បីឱ្យប្រជាពលរដ្ឋចូលជាសមាជិកសហគមន៍នេសាទ យ៉ាងហោចណាស់លើសពីពាក់កណ្តាលនៃចំនួនគ្រួសារអ្នកនេសាទសរុប នៅកន្លែងនោះ។ ក្នុងករណីដែលចំនួនអ្នកចូលរួមពុំបានចំនួនភាគច្រើន គ្រប់តាមការកំណត់ខាងលើគឺត្រូវបន្តខិតខំធ្វើការផ្សព្វផ្សាយបន្ថែមទៀត"* ។

គោលបំណងនៃជំហាននេះគឺជំរុញប្រជានេសាទដែលមានជំនាញ និងបទពិសោធន៍ឱ្យពួកគាត់ចូលជាសមាជិក និងចូលរួមឱ្យបានសកម្ម។ ក្រុមស្ត្រីត្រូវបានលើកទឹកចិត្តឱ្យចូលជាសមាជិកសហគមន៍នេសាទ។

ប្រជានេសាទអាចគ្រប់គ្រងធនធានជលផល អាចដោះស្រាយបញ្ហាសេដ្ឋកិច្ចសង្គម និងតម្រូវការ និងបង្កើនការយល់ដឹង ព្រមទាំងយល់ដឹងអំពីការគ្រប់គ្រងរបស់ពួកគាត់ និងគ្រប់គ្រងធនធានជលផល ក្នុងបរិបទប្រពន្ធ័អេកូឡូស៊ី ។

## ៤.៣ ជំហានទី២÷ ការសិក្សាលទ្ធភាពបង្កើតសហគមន៍នេសាទ

បន្ទាប់ពីបានដាក់ពាក្យស្នើសុំបង្កើតសហគមន៍នេសាទ ក្រុមស្ថាបនិកដែលមានការគាំទ្រពីខណ្ឌរដ្ឋបាល ជលផលត្រូវរៀបចំសិក្សាវាយតម្លៃ និងប្រមូលព័ត៌មានដាក់លាក់ទាក់ទងនឹង ក)ស្ថានភាពសេដ្ឋកិច្ចសង្គម ខ)ស្ថានភាពនេសាទ គ)ស្ថានភាពដែននេសាទ ឃ)សកម្មភាពនានាទាក់ទងទៅនឹងការនេសាទ ង)ស្ថានភាពទាក់ទងនឹងកសិកម្ម ច)បញ្ហាកើតឡើងក្នុងសហគមន៍នេសាទទាក់ទងនឹងវិស័យជលផល។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

**ការវាយតម្លៃអំពីលទ្ធភាពបង្កើតសហគមន៍នេសាទរួមមាន៖**

- ការវាយតម្លៃអំពីធនធាន និងបរិស្ថាន៖ (ដីធ្លី ស្ទឹង ទន្លេ អាកាសធាតុ .....)
- ការវាយតម្លៃសេដ្ឋកិច្ចសង្គម៖ ការកំណត់លក្ខខណ្ឌសង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយនៅក្នុងមូលដ្ឋាន
- ការវាយតម្លៃអំពីលិខិតបទដ្ឋាន និងស្ថាប័ន៖ ការកំណត់រចនាសម្ព័ន្ធស្ថាប័ន និងអភិបាលកិច្ចសម្រាប់គ្រប់គ្រងធនធាននៅសហគមន៍
- ការសិក្សាសង្ខេបអំពីស្ថានភាពកសិកម្ម៖ ចំនួនប្រជាពលរដ្ឋ ប្រកបរបរកសិកម្ម ដំណាំជាចម្បង
- ការសិក្សាលម្អិតអំពីជលផល៖ ចំនួនអ្នកនេសាទ ប្រភេទទូក និងឧបករណ៍នេសាទ ប្រភេទត្រីនេសាទ និងកន្លែងនេសាទ
- ការសិក្សាបញ្ហាទាក់ទងទៅនឹងវិស័យជលផល៖ បញ្ហាប្រឈម និងឱកាស

## ៤.៤ ជំហានទី៣៖  ការផ្សព្វផ្សាយ និងចុះឈ្មោះសមាជិកសហគមន៍នេសាទ

ក្រុមស្ថាបនិកមានភារកិច្ច ចុះឈ្មោះប្រជាពលរដ្ឋដែលស្មគ្រ័ចូលជាសមាជិកសហគមន៍-នេសាទ។ ក្រុមស្ត្រីត្រូវបានលើកទឹកចិត្តឱ្យចូលរួមជា សមាជិកសហគមន៍នេសាទ។

ដោយមានការសម្របសម្រួលពីខណ្ឌរដ្ឋបាលជលផល ក្រុមស្ថាបនិកត្រូវ៖

- ការផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋអំពីផលប្រយោជន៍នៃការបង្កើតសហគមន៍នេសាទ ដើម្បីឱ្យចូលជាសមាជិកសហគមន៍នេសាទ(យ៉ាងហោចណាស់៥០%នៃចំនួនគ្រួសារអ្នកនេសាទសរុបនៅកន្លែងនោះ)
- ចុះបញ្ជីឈ្មោះអ្នកស្ម័គ្រចិត្តចូលរួមជាសមាជិកសហគមន៍នេសាទ
- រៀបចំត្រៀមបេក្ខភាពឈរឈ្មោះបោះឆ្នោតជាគណៈកម្មការសហគមន៍នេសាទ (មិនមានការណែនាំជាក់លាក់អំពីការជូនដំណឹងទេ តែជាធម្មតាតែងមានកិច្ចប្រជុំដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ)។ អ្នកសម្របសម្រួលត្រូវធានាថាសមាជិកគ្រប់រូបបានដឹង និងមានឱកាសឈរឈ្មោះឱ្យគេបោះឆ្នោត
- រៀបចំដំណើរការមហាសន្និបាតលើកដំបូងដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- ធ្វើលិខិតអញ្ជើញចូលរួមមហាសន្និបាត
- រៀបចំអង្គប្រជុំផ្សេងៗពាក់ព័ន្ធនឹងការត្រៀមធ្វើមហាសន្និបាត
- រៀបចំសេចក្តីព្រាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងដោយមានការពិគ្រោះយោបល់។



### គន្លឹះសម្រាប់អ្នកសម្របសម្រួល

ក្រុមស្ថាបនិកត្រូវវាយតម្លៃ ថាតើសមាជិកសហគមន៍ទាំងអស់ ត្រៀមខ្លួនជាស្រេច និងបង្ហាញការប្តេជ្ញាចិត្ត ចំពោះដំណើរការសហគមន៍នេសាទហើយឬនៅ? ព័ត៌មាន ៣ ដែលត្រូវរកឱ្យឃើញ៖ ១)ការយល់ដឹងអំពីបញ្ហាជលផលនិងបរិស្ថាន ២) ក្តីបារម្ភអំពីបញ្ហាជលផល និង៣) ឆន្ទៈក្នុងការដោះស្រាយបញ្ហាទាំងនោះ។ ក្រុមស្ថាបនិកត្រូវព្រមព្រៀងឯកភាពផ្ទៃក្នុងអំពីចំណាប់អារម្មណ៍ និងក្តីបារម្ភ ដែលត្រូវស្នើឱ្យរដ្ឋបាលជលផលជួយសម្របសម្រួល និងដោះស្រាយ។

ការសិក្សាអំពីសុវត្ថិភាព៖ នៅក្នុងសហគមន៍នេសាទប្រមូលផ្តុំដោយមនុស្សជាច្រើន ដូចជាមនុស្សចាស់ យុវជន យុវនារី ស្ត្រី និងជនជាតិដើមភាគតិច។ល។ នៅគ្រប់ដំណើរការនៃការរៀបចំសហគមន៍នេសាទ រាប់ចាប់ពីការផ្សព្វផ្សាយបំផុសឱ្យមានការចូលរួម ការពិគ្រោះយោបល់ រហូតដល់ការបោះឆ្នោត ត្រូវធានាថាសមាជិក មានឱកាសចូលជាសមាជិកសហគមន៍នេសាទ។ ក្នុងករណីមានជនជាតិដើមភាគតិចច្រើនក្រុមក្នុងឃុំ សង្កាត់ ត្រូវអនុវត្តតាមក្របខណ្ឌអភិវឌ្ឍន៍ សម្រាប់ជនជាតិដើមភាគតិច។

ក្រុមស្ថាបនិកត្រូវផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋឱ្យបានយល់ដឹងអំពីសារៈប្រយោជន៍នៃការរៀបចំសហគមន៍នេសាទ ដើម្បីឱ្យពួកគាត់ស្ម័គ្រចិត្តចូលរួមជាសមាជិកសហគមន៍នេសាទ។

## ៤.៥ ជំហានទី៤÷ ការរៀបចំទស្សនៈវិស័យ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

- **ទស្សនៈវិស័យ** ជាការរៀបរាប់អំពីស្ថានភាព ដែលសមាជិកសហគមន៍នេសាទ ចង់បាននាពេលអនាគត (លទ្ធផលរយៈពេលវែង)
- **លក្ខន្តិកៈ** ជានីតិវិធីរដ្ឋបាល កំណត់ពីរបៀបសហគមន៍នេសាទដែលត្រូវបង្កើតឡើង និងដំណើរការរបស់វា (ការកត់ត្រា ការបោះឆ្នោតគណៈកម្មការសហគមន៍នេសាទ។ល។)
- **បទបញ្ជាផ្ទៃក្នុង** រៀបរាប់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក និងការងាររបស់សហគមន៍នេសាទ (ដូចជាកិច្ចប្រជុំជាដើម)។



### គន្លឹះសម្រាប់អ្នកសម្របសម្រួល

យោងតាមប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ ជំពូកទី៣ ប្រការ៨ ចែងថា៖ *សមាជិកក្រុមសម្របសម្រួល និងក្រុមស្ថាបនិកត្រូវចាត់ចែងការប្រជុំពិគ្រោះយោបល់ ជាមួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានលើសេចក្តីព្រាងលក្ខន្តិក និងបទបញ្ញាផ្ទៃក្នុង ដើម្បីដាក់ជូនមហាសន្និបាតសហគមន៍នេសាទធ្វើការអនុម័ត។*

- ទស្សនៈវិស័យ ជាការរៀបរាប់អំពីស្ថានភាព ដែលសមាជិកសហគមន៍នេសាទ ចង់បាននៅពេលអនាគត ។ វាជាលទ្ធផលដែល សហគមន៍នេសាទចង់សម្រេចឱ្យបាន ឬលទ្ធផលរយៈពេលវែង។ ទស្សនៈវិស័យត្រូវបានឆ្លើយនឹងសំណួរ (តើយើងអាចសម្រេចនូវអ្វីដែល

យើងចង់ធ្វើដែរឬទេ ហើយវាមានរូបរាងដូចម្ដេច នៅពេលអនាគតណាមួយ? ឧទា. រយៈពេល៥ឆ្នាំខាងមុខ)

- លក្ខន្តិក ជានីតិវិធីរដ្ឋបាល កំណត់ដំណើរការសហគមន៍នេសាទ
- បទបញ្ជាផ្ទៃក្នុង រៀបរាប់អំពីការអនុញ្ញាត និងការហាមឃាត់ (សិទ្ធិនិងកាតព្វកិច្ចរបស់សមាជិក) និងរបៀបដែលសហគមន៍នេសាទប្រតិបត្តិ។

## ៤.៦ ជំហានទី៥៖ ការធ្វើសន្និបាតលើកដំបូងជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

មហាសន្និបាតរបស់សហគមន៍នេសាទគឺជាអង្គប្រជុំកំពូល ដើម្បីអនុម័ត និងធ្វើសេចក្ដីសម្រេចចិត្តទាំងឡាយក្នុងនាមសហគមន៍នេសាទ។

មហាសន្និបាតលើកដំបូងត្រូវបានរៀបចំឡើង ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការ។

សហគមន៍នេសាទ និងអនុម័តទៅលើកិច្ចការសំខាន់ៗដូចជា៖ សមាជិកសហគមន៍នេសាទ ឈ្មោះសហគមន៍នេសាទ លក្ខន្តិក និងបទបញ្ជាផ្ទៃក្នុង គណៈកម្មការរៀបចំបោះឆ្នោត ចំនួនគណៈកម្មការ សមាសភាពឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទ។



### គន្លឹះសម្រាប់អ្នកសម្របសម្រួល

មហាសន្និបាតលើកដំបូងរបស់សហគមន៍នេសាទមានគោលបំណង៖

- យល់ព្រមលើបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- ឯកភាពលើលក្ខន្តិក និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
- យល់ព្រម និងឯកភាពលើចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ
- ជ្រើសរើសគណៈកម្មការរៀបចំការបោះឆ្នោតគណៈកម្មការសហគមន៍នេសាទ បញ្ជីរាយនាមបេក្ខជន
- ដំណើរការបោះឆ្នោត និងប្រកាសលទ្ធផលគណៈកម្មការសហគមន៍នេសាទ។

## ៤.៧ តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ

សមាជិកសហគមន៍នេសាទ ត្រូវចូលរួមបោះឆ្នោតជ្រើសរើសគណៈកម្មការដើម្បីឱ្យទទួលបន្ទុកគ្រប់គ្រងសហគមន៍នេសាទ។

គណៈកម្មការសហគមន៍នេសាទមានសិទ្ធិ ដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទ។ គណៈកម្មការសហគមន៍នេសាទកើតឡើងតាមរយៈការបោះឆ្នោត។ សមាជិកម្នាក់ៗដែលមានសញ្ជាតិខ្មែរពីកំណើតអាចជាឈរឈ្មោះជាបេក្ខជនគណៈកម្មការសហគមន៍នេសាទបាន។ គណៈកម្មការសហគមន៍នេសាទមានអាណត្តិការងាររយៈពេល៥ឆ្នាំ។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

គណៈកម្មការសហគមន៍នេសាទមានភារកិច្ចៈ

- រៀបចំ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- រៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទទួលបានការឯកភាពពីខណ្ឌរដ្ឋបាលជលផល និងរដ្ឋបាលជលផលថ្នាក់កណ្តាល
- គ្រប់គ្រងការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- វាយតម្លៃ និងពិនិត្យឡើងវិញនូវផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជាមួយនឹងខណ្ឌរដ្ឋបាលជលផល
- រៀបចំរបាយការណ៍ប្រចាំត្រីមាស និងដាក់ជូនខណ្ឌរដ្ឋបាលជលផល និងរាយការណ៍អំពីការបំពានច្បាប់នានា
- ដោះស្រាយវិវាទដែលមានក្នុងសហគមន៍នេសាទ
- បើកគណនីធនាគារ និងគ្រប់គ្រងហិរញ្ញវត្ថុរបស់សហគមន៍
- រៀបចុះកិច្ចប្រជុំ និងពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍
- ធ្វើការសម្រេចចិត្ត ដោយឈរលើការឯកភាពពីសមាជិកភាគច្រើន។

## ៤.៨ ជំហានទី៦៖ ការកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍

ការធ្វើផែនទីកន្លែងនេសាទសហគមន៍ដើម្បីកំណត់ច្បាស់អំពីដែននេសាទដែលត្រូវគ្រប់គ្រង និងស្ថិតក្នុងការអនុវត្តនៃបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ។



### គន្លឹះសម្រាប់អ្នកសម្របសម្រួល

ដូចមានរៀបរាប់ ក្នុងប្រកាស ស្ដីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ ជំពូកទី៦ ប្រការ១៧ ចែងថា៖ "*ការកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍ ត្រូវមានការពិគ្រោះយោបល់ នៅមូលដ្ឋានសហគមន៍នេសាទឱ្យបានច្បាស់លាស់។ គណៈកម្មការកំណត់ព្រំប្រទល់រៀបចំផែនទីកន្លែងនេសាទសហគមន៍ហើយដោះស្រាយវិវាទត្រូវបង្កើត និងដឹកនាំដោយរដ្ឋបាលជលផលថ្នាក់កណ្ដាល*"។

ក្រោយពីការកំណត់ព្រំប្រទល់រួច សហគមន៍នេសាទត្រូវធ្វើផែនទី និងធ្វើសុពលភាព តាមរយៈការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសហគមន៍ជិតខាង។

តាមពិតទៅព្រំប្រទល់ដែននេសាទសហគមន៍ ត្រូវតែស៊ីសង្វាក់គ្នាជាមួយនឹងប្រពន្ធ័អេកូឡូស៊ីជាក់លាក់។ ទោះជាយ៉ាងណា កន្លែងនេសាទសហគមន៍ត្រូវបានដំណើរការនៅក្នុងបរិបទសេដ្ឋកិច្ច សង្គម និងនយោបាយ។ ភាពប្រឈមរបស់យើងគឺការរៀបចំសហគមន៍នេសាទឱ្យមានទំហំ និងវិសាលភាពសមស្រប ក្នុងការឆ្លើយតបនឹងតម្រូវការផ្នែកនយោបាយ សង្គម វប្បធម៌ និងប្រពន្ធ័

អេកូឡូស៊ី ។ បើសិនជាអាច ក្នុងការកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ ត្រូវពិនិត្យអន្តរទំនាក់ទំនងរវាង ១) ជម្រកវារីសត្វ និងលក្ខខណ្ឌរស់នៅ ២) ប្រភេទវារីសត្វ ធនធានធម្មជាតិ (ភាពចម្រុះ ភាពសម្បូរ និងបរិមាណ) និង ៣) របៀបដែលមនុស្សប្រើប្រាស់ធនធាន។

ក្រោយពីការកំណត់ព្រំប្រទល់រួច សហគមន៍ត្រូវធ្វើផែនទី និងធ្វើសុពលភាពតាមរយៈការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសហគមន៍នេសាទជិតខាង ។

## ៤.៩ ជំហានទី៧៖ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

**កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍** គឺជាកិច្ចព្រមព្រៀង ជាផ្លូវការរវាងសហគមន៍នេសាទ និងរដ្ឋបាលជលផលដែលទទួលស្គាល់ និងធានាសិទ្ធិរបស់សហគមន៍នេសាទចំពោះកន្លែងនេសាទសហគមន៍ ដែលបានធ្វើផែនទី។

នៅក្នុងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ មានចែងច្បាស់អំពី៖

- តួនាទី និងការទទួលខុសត្រូវរបស់ភាគីនីមួយៗ
- ទីកន្លែង និងទំហំដែននេសាទ
- លក្ខខណ្ឌ និងពេលវេលានៃការគ្រប់គ្រង និងការប្រើប្រាស់ឧបករណ៍នេសាទ
- លក្ខខណ្ឌនៃវិសោធនកម្ម និងការបញ្ចប់កិច្ចព្រមព្រៀង។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍គឺជាកិច្ចព្រមព្រៀងតាមលក្ខណៈច្បាប់ ដោយរដ្ឋបាលជលផល ក្នុងការផ្ទេរដែននេសាទទៅឱ្យសហគមន៍នេសាទគ្រប់គ្រងប្រកបដោយនិរន្តរភាពក្នុងរយៈពេល៣ឆ្នាំ។ នៅក្នុងកិច្ចព្រមព្រៀងមានបញ្ជាក់ពីឧបករណ៍នេសាទ តួនាទីរបស់ខណ្ឌរដ្ឋបាលជលផលក្នុងការគាំទ្រសហគមន៍នេសាទ និងនីតិវិធីរាយការណ៍អំពីការបំពាននានា។

ដើម្បីឱ្យកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍មានសុពលភាពត្រូវមានភាគីពីរចុះហត្ថលេខាគឺនាយខណ្ឌរដ្ឋបាលជលផល និងគណៈកម្មការសហគមន៍នេសាទ និងហត្ថលេខារបស់របស់មេឃុំចៅសង្កាត់ ក្នុងនាមជាសាក្សី។

យោងតាមប្រកាស ស្ដីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទជំពូកទី៨ ប្រការ២១ចែងថា៖ ឯកសារនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវមានភ្ជាប់ជាមួយនូវ៖

- ផែនទី (មាត្រដ្ឋាន ១/៥០០០០) បង្ហាញពីទំហំកន្លែងនេសាទសហគមន៍ ដោយមានប្រព័ន្ធកូអ័រដោនេ(អាប់ស៊ីស និងអ័រដោនេ) ច្បាស់លាស់។
- បញ្ជីឈ្មោះសមាជិកសហគមន៍ និងគណៈកម្មការសហគមន៍នេសាទ
- ឯកសារលក្ខន្តិក និងបទបញ្ជាផ្ទៃក្នុង
- លិខិតបញ្ជាក់ពីគោលបំណងបង្កើតសហគមន៍នេសាទ និងការគ្រប់គ្រងធនធានជលផល

គណៈកម្មការសហគមន៍នេសាទត្រូវបិទផ្សាយកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ នៅទីសាធារណៈ ដែលងាយស្រួលអាននៅឃុំសង្កាត់ ក្រុងស្រុក និងរាជធានីខេត្តរយៈពេល ៣០ថ្ងៃ មុននឹងដាក់រដ្ឋបាលជលផលពិនិត្យ និងឯកភាព។

## ៤.១០ ជំហានទី៨៖  ការចុះបញ្ជី និងការទទួលស្គាល់សហគមន៍នេសាទ

ក្រោយពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ នាយខណ្ឌរដ្ឋបាលជលផលរាជធានី ខេត្ត ត្រូវធ្វើសំណើទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសុំចុះបញ្ជី និងចេញប្រកាសទទួលស្គាល់ជាផ្លូវការ។



## ៤.១១ ជំហានទី៩៖ ការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក្រោយពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គណៈកម្មការសហគមន៍ត្រូវរៀបចំផែនការគ្រប់គ្រងសម្រាប់កន្លែងនេសាទសហគមន៍។

- គឺជាឯកសារដែលរៀបចំដោយគណៈកម្មការសហគមន៍នេសាទ និងមានការឯកភាពពីរដ្ឋបាលជលផល។
- ផែនការមានបញ្ជាក់ពីការគ្រប់គ្រងធនធានជលផល និងសកម្មភាព និងតួនាទី ភារកិច្ចរបស់សមាជិកសហគមន៍ និងរាជរដ្ឋាភិបាល។
- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវមានចំណុចសំខាន់ៗដូចជា៖ វិធានការការគ្រប់គ្រងធនធានជលផល ការគ្រប់គ្រងវិវាទក្នុងសហគមន៍នេសាទ ការគោរព និងការពង្រឹងការអនុវត្តច្បាប់ រួមទាំងការរៀបរាប់លម្អិតអំពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ។
- នៅគ្រប់ជំហាននៃដំណើរការកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានដឹកនាំដោយគណៈកម្មការសហគមន៍នេសាទ និងមានការចូលរួមពីសមាជិកសហគមន៍នេសាទ ខណ្ឌរដ្ឋបាលជលផល រួមទាំងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់។
- នៅពេលមានការឯកភាពរួចហើយ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

យោងតាមប្រកាស ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ ជំពូកទី៩ ប្រការ២២ ចែងថា៖ ខ្លឹមសារនៃផែនការបញ្ជាក់អំពីយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ក្នុងការគ្រប់គ្រងធនធានជលផល និងតួនាទី ភារកិច្ចរបស់សមាជិកសហគមន៍នេសាទ ស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ។

*សហគមន៍នេសាទត្រូវរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។*

*ការរៀបចំផែនការគ្រប់គ្រងគឺដើម្បីកំណត់៖*

- យុទ្ធសាស្ត្រ និងសកម្មភាពគ្រប់គ្រងធនធានជលផល
- តួនាទី និងភារកិច្ចរបស់សហគមន៍នេសាទ និងស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល។

នៅក្នុងផែនការគួរបញ្ចូល៖

- បញ្ហាបរិស្ថាន (ឧទា. ផលប៉ះពាល់លើជម្រកពងកូនចំពោះប្រភេទត្រីខ្លះ)
- បញ្ហាសង្គម (ឧទា. ការវិវាទ សុខភាពនិងសុវត្ថិភាព និងការកែច្នៃផលនេសាទ)
- បញ្ហាអភិបាលកិច្ច (ឧទា. ដំណើរការពិគ្រោះយោបល់ និងការចូលរួមរបស់ស្ត្រី)

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវរៀបចំជាភាសាខ្មែរ មិនមានពាក្យបច្ចេកទេស និងមានកម្រាស់ប្រហែល១៥ទំព័រ។




ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បង្ហាញអំពីៈ

- បញ្ហាចម្បងអ្វីខ្លះដែលសហគមន៍នេសាទត្រូវដោះស្រាយ (រួមទាំងការចាត់អាទិភាព)
- លទ្ធផលអ្វីខ្លះដែលគេចង់បាន
- សកម្មភាពចម្បងៗអ្វីខ្លះ ដើម្បីសម្រេចគោលបំណង និងគោលដៅ
- ឧបករណ៍ និងសកម្មភាពអ្វីខ្លះដែលទាក់ទងនឹងការអនុវត្តច្បាប់ និងពង្រឹងការអនុវត្តច្បាប់
- លទ្ធផលនីមួយៗត្រូវបានវាស់វែងយ៉ាងដូចម្តេច (សូចនាករ)
- ឧបករណ៍អ្វីខ្លះដែលទាក់ទងនឹងការដោះស្រាយវិវាទ
- រយៈពេលប៉ុន្មាន ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ (ពេលចាប់ផ្តើមនិងបញ្ចប់ សកម្មភាពនីមួយៗ)
- អ្នកណាជាអ្នកអនុវត្តសកម្មភាព
- អ្នកណាទទួលខុសត្រូវអនុវត្តសកម្មភាព
- សហគមន៍នេសាទមានតម្រូវការគាំទ្រពីអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធអ្វីខ្លះ
- តម្រូវការថវិកាប៉ុន្មាន និងបានពីណា។

វិធានការផ្នែកគ្រប់គ្រង រួមមានៈ

- ការត្រួតពិនិត្យផលចាប់
- ការត្រួតពិនិត្យអ្នកនេសាទ និងមធ្យោបាយនេសាទ

- ការត្រួតពិនិត្យដែននេសាទ (ឧទា.កន្លែងអភិរក្ស និងតំបន់ការពារ)
- ការត្រួតពិនិត្យពេលវេលានេសាទ (ឧទា.រដូវបើក និងបិទនេសាទ)
- ការត្រួតពិនិត្យ ការចេញចូលនេសាទ (ឧទា. អនុញ្ញាតឱ្យចូល ឬហាមចូលនេសាទ)
- វិធានការការពារ និងកែលម្អជម្រកត្រី (ឧទា. ការពារជម្រកពងកូន)។

### គន្លឹះសម្រាប់អ្នកសម្របសម្រួល

នៅក្នុងឧបសម្ព័ន្ធទី៤នៃ ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទបានបង្ហាញពីគំរូនៃការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ។ វាជាគំរូទូទៅមួយ ដែលសហគមន៍នេសាទត្រូវបំពេញព័ត៌មានដែលមានស្រាប់ ត្រង់ចន្លោះទំនេរ ។ ទម្រង់នោះដូចជាមិនបានផ្តល់ការណែនាំជាក់លាក់សម្រាប់ការរៀបចំទេ។

## ៤.១២ សកម្មភាពយេនឌ័រនៅក្នុងការរៀបចំផែនការគ្រប់គ្រង

ទិដ្ឋភាព និងសកម្មភាពដែលទាក់ទងនឹងយេនឌ័រ គួរត្រូវបានបញ្ចូលក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍មានដូចជាៈ

- គោលដៅ និងគោលបំណង ដែលឆ្លើយតបនឹងតម្រូវការរបស់បុរស និងស្ត្រី
- ការវិនិយោគលើការកែលម្អការបច្ចេកទេសកែច្នៃផលនេសាទដែលក្រុមស្ត្រីត្រូវការ
- សកម្មភាពនានា ដែលលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងគណៈកម្មការសហគមន៍នេសាទ
- ការបណ្តុះបណ្តាលដែលលើកកម្ពស់សមធម៌ និងសមភាពស្ត្រី ក្នុងវិស័យវារីវប្បកម្ម និងជលផល។

កិច្ចប្រជុំជាមួយក្រុមស្ត្រីគួរត្រូវបានរៀបចំដោយឡែក ដើម្បីកំណត់បញ្ហាតម្រូវការ និងឱកាសរបស់ស្ត្រី ហើយនិងបញ្ចូលបញ្ហា តម្រូវការ និងឱកាសទាំងនោះទៅក្នុងផែនការ។




## ៤.១៣ សេចក្តីសង្ខេប

តួនាទី និងភារកិច្ចរបស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីការបង្កើតសហគមន៍នេសាទ តាមរយៈ សហគមន៍នេសាទ ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាស៖

| តួនាទី និងការទទួលខុសត្រូវ | ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | រដ្ឋបាលជលផល ថ្នាក់កណ្តាល | មន្ទីរកសិកម្ម/ ខណ្ឌរដ្ឋបាល ជលផល | អាជ្ញាធរ មូលដ្ឋាន |
|---|---|---|---|---|
| បង្កើត និងចូលរួមជាមួយ ក្រុមសម្របសម្រួល | | | ✓ | |
| សិក្សាលទ្ធភាពបង្កើតសហគមន៍នេសាទ | | | ✓ | |
| ឯកភាពលើសំណោះរបស់ក្រុមស្ថាបនិក បង្កើតសហគមន៍នេសាទ | | | ✓ | |
| ជួយសម្របសម្រួលការងាររបស់ក្រុមស្ថាបនិក | | | ✓ | ✓ |
| រៀបចំការផ្សព្វផ្សាយបំផុសដល់ប្រជាពលរដ្ឋ | | | ✓ | ✓ |

| | | | | |
|---|---|---|---|---|
| រៀបចំកិច្ចប្រជុំពិគ្រោះយោបល់អំពីសេចក្តីព្រាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | | | ✓ | ✓ |
| រក្សាទុក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ | | | ✓ | ✓ |
| ការបង្កើតក្រុមស្ថាបនិក និងសំណើសុំបង្កើត សហគមន៍នេសាទ | | | ✓ | ✓ |
| ការកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍ | | ✓ | ✓ | ✓ |
| កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ | | | ✓ | ✓ |
| ការចុះបញ្ជី និងការទទួលស្គាល់សហគមន៍នេសាទ | ✓ | ✓ | ✓ | ✓ |
| ការកសាង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | ✓ | ✓ | ✓ |
| តាមដានត្រួតពិនិត្យការអនុវត្តច្បាប់ | | | ✓ | ✓ |
| វាយតម្លៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | ✓ | ✓ |
| ពិនិត្យរបាយការដែលសហគមន៍នេសាទ ផ្ញើមកឱ្យ | | | ✓ | ✓ |
| រៀបចំរបាយការណ៍ និងដាក់ជូនទៅរដ្ឋបាលជលផល | | | ✓ | |
| ដោះស្រាយវិវាទ | | | ✓ | ✓ |
| រំសាយសហគមន៍នេសាទ | ✓ | ✓ | ✓ | ✓ |

## ៥. ការគ្រប់គ្រងវិវាទ

គោលដៅនៃការគ្រប់គ្រងវិវាទ គឺមិនមែនដើម្បីជៀសវាងវិវាទនោះទេ ប៉ុន្តែដើម្បីជួយពួកគេដោះស្រាយបញ្ហារបស់ពួកគេតាមរបៀបសហការ។

ការគ្រប់គ្រងវិវាទរួមមាន៖

- **ការចរចារ៖** ភាគីជួបទល់មុខគ្នា ដោយមាន ឬគ្មានអ្នកសម្រុះសម្រួល ដើម្បីឈានទៅដល់ដំណោះស្រាយដែលអាចទទួលយកបាន។
- **ការសម្រុះសម្រួល៖** អ្នកសម្រុះសម្រួល (ភាគីទីបីអព្យាក្រឹត) ជួយភាគីដែលមានវិវាទឈានដល់កិច្ចព្រមព្រៀង ប៉ុន្តែមិនមានអំណាចបង្ខំឱ្យភាគីមានវិវាទយល់ព្រមលើដំណោះស្រាយឡើយ។
- **ការផ្សះផ្សា៖** អ្នកសម្របសម្រួលធ្វើការទាក់ទងដាច់ដោយឡែកពីគ្នាជាមួយភាគីវិវាទដើម្បីកាត់បន្ថយភាពតានតឹង និងឈានដល់ការព្រមព្រៀងលើដោះស្រាយវិវាទ។
- **អាជ្ញាកណ្តាល៖** អ្នកសម្រុះសម្រួលធ្វើការទាក់ទងជាមួយភាគីដែលមានជម្លោះ និងមានសិទ្ធិ ដាក់ចេញនូវដំណោះស្រាយ។

យន្តការដោះស្រាយវិវាទ គួររួមបញ្ចូលនូវ៖

- ការដោះស្រាយវិវាទដំបូងៗ (ពេលដែលភាគី ទាំងអស់ត្រៀមនឹងដោះស្រាយ)
- វិវាទធំៗ (ពេលដែល ភាគីទាំងអស់ទំនងជាមិនឯកភាពគ្នា)។

យោងតាមករណីនីមួយ ត្រូវពិចារណា៖

- អ្នកណា ជាអ្នកជួយដោះស្រាយ
- អ្នកណា ជាអ្នកសម្រេច ក្នុងករណីដែលមិនមានការឯកភាពគ្នា។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ ជំពូក១១ ប្រការ៣៣ចែងថាៈ វិវាទទាំងឡាយក្នុងសហគមន៍នេសាទត្រូវដោះស្រាយដូចខាងក្រោមៈ

- *គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងក្នុងសហគមន៍របស់ខ្លួន។*
- *ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផល ដើម្បីដោះស្រាយតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់។*
- *ក្នុងករណីដែលវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងខណ្ឌរដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងនោះទៅតុលាការរាជធានី ខេត្តសាមី ដើម្បីដោះស្រាយ តាមផ្លូវច្បាប់។*

សហគមន៍នេសាទណាមួយដែលមានយន្តការគ្រប់គ្រងវិវាទ សហគមន៍នេសាទនោះទំនងជាទទួលបានជោគជ័យ (សម្រេចគោលដៅ និងគោលបំណង ផ្នែកបរិស្ថាន និងគោលដៅផ្នែកសង្គម) ច្រើនជាងសហគមន៍នេសាទដែលគ្មានយន្តការគ្រប់គ្រងវិវាទ។

គោលដៅនៃការគ្រប់គ្រងវិវាទ គឺមិនមែនដើម្បីជៀសវាងវិវាទនោះទេ ប៉ុន្តែដើម្បីជួយពួកគេដោះស្រាយបញ្ហារបស់ពួកគេតាមរបៀបសហការ។

## ៦. ការគោរពច្បាប់ និងការពង្រឹងការអនុវត្តច្បាប់

ការពង្រឹងការអនុវត្តច្បាប់មានន័យទូលំទូលាយជាងការឃាត់ខ្លួនជនល្មើស។ កិច្ចការនេះរួមមានៈការអនុវត្តវិធីសាស្ត្រនានារបស់ស្ថាប័នផ្សេងៗ និងអ្នកពាក់ព័ន្ធក្នុងការផ្លាស់ប្តូរផ្នត់គំនិតរបស់ជនល្មើស។ ការពង្រឹងការអនុវត្តច្បាប់រួមមានវិធីសាស្ត្រច្រើនក្នុងការផ្លាស់ប្តូរផ្នត់គំនិតរបស់ជនល្មើស។ ការពង្រឹង ការអនុវត្តច្បាប់មានវិធីសាស្ត្រទន់ភ្លន់ និងវិធានការក្តៅ។

**វិធានការតឹងរ៉ឹង** ដែលអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ច និងតុលាការ ដើម្បីឱ្យមនុស្សរាងចាល។ វិធានការនេះមានគោលបំណងដើម្បីកំណត់ជនល្មើស កំណត់ទីតាំង និងបង្ក្រាបជនល្មើសដោយប្រើប្រាស់គ្រប់រូបភាពនៃទិដ្ឋភាពច្បាប់។

**វិធានការទន់ភ្លន់** ជំរុញការអនុវត្តច្បាប់ដោយស្ម័គ្រចិត្ត និងមិនបញ្ជូនទៅតុលាការ។ វិធានការទន់ភ្លន់ផ្តោតលើៈ ក) ប្រជាពលរដ្ឋកាន់ច្រើនចូលរួមគោរពច្បាប់ ខ) លើកទឹកចិត្តដល់ការអនុវត្តច្បាប់ដោយស្ម័គ្រចិត្ត និង គ) បង្កើនការបង្ការទុកជាមុន។

### គន្លឹះសម្រាប់អ្នកសម្របសម្រួល

វិធានការទន់ភ្លន់ជំរុញការអនុវត្តច្បាប់ដោយស្ម័គ្រចិត្ត និងមិនបញ្ជូនទៅតុលាការ។ វិធានការទន់ភ្លន់ផ្តោតលើៈ ក) ប្រជាពលរដ្ឋកាន់ច្រើនចូលរួមគោរពច្បាប់ ខ) លើកទឹកចិត្តដល់ការអនុវត្តច្បាប់ដោយស្ម័គ្រចិត្ត និង គ) បង្កើនការបង្ការទុកជាមុន។ វិធានការទន់ភ្លន់រួមមានៈ

- ការផ្សព្វផ្សាយក្នុងសង្គមដូចជាៈ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទំនាក់ទំនងសាធារណៈ ការប្រាស្រ័យទាក់ទង ការចូលរួមពីបុគ្គលល្បី (តារាកំប្លែង អ្នកជំនាញ វាគ្មិនកិត្តិយស) និងការស្វែងរកការគាំទ្រមតិ
- ការប្រាស្រ័យទាក់ទងសង្គមដូចជាៈ សិក្ខាសាលា កិច្ចប្រជុំ ទស្សនកិច្ចសិក្សា ទស្សនកិច្ចផ្លាស់ប្តូរ បទពិសោធន៍ ការស្វែងរកការគាំទ្រមតិ វេទិកាសាធារណៈ ការសម្តែងរឿងខ្លីៗ គណៈកម្មការសហគមន៍នេសាទ ក្រុមល្បាត ក្រុមឃ្លាំមើល និងការបញ្ចូលក្នុងកម្មវិធីសិក្សាជាដើម
- ការអប់រំ និងការផ្សព្វផ្សាយព័ត៌មានដល់មូលដ្ឋាន តាមរយៈទូរទស្សន៍ វីដេអូ កាសែត ព្រឹត្តប័ត្រព័ត៌មាន កំប្លែង រូបភាព និងព័ត៌មាន

- ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

វិធានការតឹងរ៉ឹង ដែលអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ច និងតុលាការ ដើម្បីឱ្យមនុស្សរាងចាល។ វិធានការនេះមានគោលបំណងដើម្បីកំណត់ជនល្មើស កំណត់ទីតាំង និងបង្ក្រាបជនល្មើសដោយប្រើប្រាស់គ្រប់រូបភាពនៃទិដ្ឋភាពច្បាប់។ វិធានការក្តៅរួមមាន៖

- ការពង្រឹងការអនុវត្តច្បាប់ជាបន្តបន្ទាប់ ដូចជាការល្បាតជាដើម
- សកម្មភាពស្វែងរកជាប្រចាំ ចាប់ជនល្មើស និងបញ្ជូនទៅតុលាការ និងដាក់ទណ្ឌកម្មតាមបទល្មើសជាក់ស្តែង
- មានយុទ្ធសាស្ត្រផ្សេងៗដែលប្រសើរសម្រាប់ដេញចាប់ជនល្មើសដែលមិនរាងចាលតាមរយៈ ក្រុមល្បាត ឬទូកប្រដេញ ប្រព័ន្ធត្រួតពិនិត្យ
- ធ្វើការរឹបអូសសម្ភារ ឧបករណ៍នេសាទពាក់ព័ន្ធនឹងសកម្មភាពនេសាទល្មើសច្បាប់។

## ៧. បណ្តាញ

ទំនាក់ទំនងរបស់សហគមន៍នេសាទជាមួយនឹងអង្គភាពនានាខាងក្រៅមានសារសំខាន់សម្រាប់ភាពជោគជ័យរយៈពេលវែងរបស់សហគមន៍។

ទំនាក់ទំនងជាមួយនឹង៖

- សហគមន៍នេសាទ និងគម្រោងដទៃទៀត
- អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន (ជំនួយបច្ចេកទេស និងព័ត៌មាន)
- ស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល ដែលសហគមន៍នេសាទមិនសូវមានទំនាក់ទំនងដូចជា៖ ក្រសួងពាណិជ្ជកម្ម និងសុខាភិបាលជាដើម
- អ្នកមានឥទ្ធិពល និងអំណាចដូចជា៖ អ្នកច្បាប់ អ្នកនយោបាយ និងអ្នកជំនួញធំៗ។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ការបង្កើតបណ្តាញការងារ មានសារសំខាន់ចំពោះការពាំនាំចំណាប់អារម្មណ៍ និងក្តីបារម្ភរបស់ប្រជាពលរដ្ឋ ដល់រាជរដ្ឋាភិបាលដើម្បីពិចារណា ក្នុងការផ្តល់ជំនួយបច្ចេកទេស និងចំណេះដឹង ដើម្បីសម្រេចគោលបំណងនានា ចែករំលែកបទពិសោធន៍ និងយុទ្ធសាស្ត្រការគ្រប់គ្រងធនធានជលផល ។

## ៨. តួនាទី និងភារកិច្ចរបស់ខណ្ឌរដ្ឋបាលជលផលចំពោះសហគមន៍នេសាទ

ខណ្ឌរដ្ឋបាលជលផល មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- យល់ព្រម និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- លុបចោលកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- សម្របសម្រួលដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- ឯកភាពលើបច្ចុប្បន្នភាពនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ពិនិត្យ និងឯកភាពលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ពិគ្រោះយោបល់លើការកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍
- ពិនិត្យរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆ្នាំរបស់សហគមន៍នេសាទ
- បូកសរុបរបាយការណ៍ពីសហគមន៍នេសាទ និងរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដាក់ជូនរដ្ឋបាលជលផលថ្នាក់កណ្តាល
- ផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់សហគមន៍នេសាទដូចជា៖ ការផ្សព្វផ្សាយបំផុស

ប្រជាពលរដ្ឋនិងផ្តល់អំណាចជាដើម

- បង្កើតគោលបំណងសម្រាប់សហគ្រប់គ្រងធនធានជលផល
- បង្កើតសកម្មភាពចម្បងៗដើម្បីសម្រេចគោលបំណង
- សម្របសម្រួលផែនការជាមួយសហគមន៍នេសាទ
- តាមដានត្រួតពិនិត្យសកម្មភាពសហគមន៍នេសាទនានា
- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- វាយតម្លៃការបំពេញការងាររបស់សហគមន៍នេសាទ ធៀបនឹងគោលបំណងដែលបានគ្រោងទុក។



## ៩. ការតាមដានត្រួតពិនិត្យសហគមន៍នេសាទ

យោងតាមប្រការ៣១ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ខណ្ឌរដ្ឋបាលជលផល ត្រូវតាមដានត្រួតពិនិត្យភាពរីចម្រើនរបស់សហគមន៍នេសាទ តាមរយៈកិច្ចប្រជុំ ពិនិត្យមើលគោលដៅ និងគោលបំណង ដើម្បីមានមូលដ្ឋានកែសម្រួលសហគ្រប់គ្រងធនធានជលផល។ ខណ្ឌរដ្ឋបាលជលផលអាចតាមដានត្រួតពិនិត្យប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ តាមការចាំបាច់របស់សហគមន៍នេសាទ។

ដំណើរការតាមដានត្រួតពិនិត្យរួមមាន៖

- ការស្វែងយល់គោលដៅ និងគោលបំណង ចំណុចខ្លាំង និងចំណុចកែលម្អ គណៈកម្មការសហគមន៍នេសាទ និងការចូលរួមរបស់សមាជិកសហគមន៍នៅមានការកម្រិត
- ការពិនិត្យផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ ខ្លឹមសាររបស់ផែនការរួមមាន៖ គោលដៅ និងគោលបំណង សូចនាករ ចំណុចដៅ ដែលទាំងនេះគឺជាមូលដ្ឋានសម្រាប់ត្រួតពិនិត្យភាពរីកចម្រើននិងការបំពេញការងាររបស់សហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះគណៈកម្មការ និងសមាជិកសហគមន៍នេសាទ ដោយបញ្ជាក់ពីការទទួលខុសត្រូវរបស់សមាជិកម្នាក់ៗ
- ការរៀបចំកិច្ចប្រជុំជាមួយ គណៈកម្មការសហគមន៍នេសាទ ដើម្បីពិនិត្យភាពរីកចម្រើននៃការសម្រេចគោលដៅ គោលបំណង និងសូចនាករ។ នៅក្នុងកិច្ចប្រជុំនេះ ត្រូវកៀរគរការចូលរួមពីសំណាក់សមាជិក និងគណៈកម្មការសហគមន៍នេសាទឱ្យបានច្រើន និងប្រមូលមតិយោបល់ផ្សេងៗ
- សួរសំណួរដែលពាក់ព័ន្ធ តើសកម្មភាពដែលយើងកំពុងតែធ្វើសកម្មភាពស្របតាមគោលបំណងដែរឬទេ? តើយើងកំពុងអនុវត្តវិធីសាស្ត្រដែលត្រឹមត្រូវដែរឬទេ? តើមានវិធីសាស្ត្រណាខ្លះទៀត ដែលធ្វើឱ្យបានលទ្ធផលប្រសើរជាងនេះ?
- ក្នុងករណីសហគមន៍នេសាទមានដំណើរការហើយជួបនឹងឧបសគ្គ ត្រូវរៀបចំផែនការសកម្មភាព ដើម្បីកំណត់ និងដោះស្រាយបញ្ហាទាំងនោះ
- បន្តអនុវត្តចំណុចល្អៗដែលបានរកឃើញពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃ
- មានកំណត់ហេតុនៃកិច្ចប្រជុំនីមួយៗ រក្សាទុកវាល់កំណត់ហេតុកិច្ចប្រជុំ និងចែកជូនសមាជិកគណៈកម្មការ និងខណ្ឌរដ្ឋបាលជលផល។

## ១០. ជំនួយបច្ចេកទេសទៅដល់សហគមន៍នេសាទ

ខណ្ឌរដ្ឋបាលជលផលត្រូវផ្ដល់ការគាំទ្របច្ចេកទេសដល់សហគមន៍នេសាទ នៅពេលពួកគាត់មានតម្រូវការ និងជួបឧបសគ្គ។

ដំណាក់កាលទាំង៤រួមមាន៖

- គណៈកម្មការសហគមន៍នេសាទត្រូវធ្វើសំណើសុំការគាំទ្របច្ចេកទេសមកខណ្ឌរដ្ឋបាលជលផល ដោយមានរៀបរាប់អំពីបញ្ហា និងតម្រូវការនានា
- ខណ្ឌរដ្ឋបាលជលផលវិភាគមូលហេតុ និងតម្រូវការ(អាចតាមរយៈការសម្ភាសន៍និងចុះដល់មូលដ្ឋាន) និងកំណត់សកម្មភាពនានា ដើម្បីដោះស្រាយបញ្ហាទាំងនោះ
- ខណ្ឌរដ្ឋបាលជលផលអនុវត្តសកម្មភាព ដោយផ្ដល់ព័ត៌មាន និងចំណេះធ្វើ ដើម្បីដោះស្រាយបញ្ហារួមមាន ៖ ១)រៀបចំដំណោះស្រាយ ២)អនុវត្តដំណោះស្រាយ និង ៣)ពិនិត្យជំហានបន្ទាប់ដើម្បីគាំទ្រ
- ខណ្ឌរដ្ឋបាលជលផលវាយតម្លៃ (ដែលអាចធ្វើផ្ទាល់មាត់) ថាតើដំណោះស្រាយមានប្រសិទ្ធភាពដែរឬទេ ? តើសហគមន៍ត្រូវការជំនួយបច្ចេកទេសអ្វីខ្លះទៀតដែរឬទេ?

## ១១. ការធ្វើរបាយការណ៍

របាយការណ៍រីកចម្រើនគឺជាការកត់ត្រានូវសកម្មភាព និងការបំពេញការងាររបស់សហគមន៍នេសាទ ដែលបានអនុវត្តកន្លងមក។ ខណ្ឌរដ្ឋបាលជលផលទទួលបានរបាយការណ៍ពីសហគមន៍នេសាទ បូកសរុប និងរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដាក់ជូនរដ្ឋបាលជលផលថ្នាក់កណ្ដាល។

របាយការណ៍រីកចម្រើន បំពេញចន្លោះខ្វះខាតនៃការប្រាស្រ័យទាក់ទងរវាងសហគមន៍នេសាទ និងរដ្ឋបាលជលផលថ្នាក់កណ្ដាល។ សារសំខាន់នៃរបាយការណ៍រីកចម្រើន គឺសម្រាប់ត្រួតពិនិត្យសកម្មភាពការងារនានារបស់ខណ្ឌរដ្ឋបាលជលផល និងភាពរីកចម្រើនរបស់សហគមន៍នេសាទ។

ចំណុចសំខាន់ៗ ក្នុងការរៀបចំរបាយការណ៍រីកចម្រើន៖

- ការត្រៀមសរសេររបាយការណ៍៖ កំណត់គោលបំណងរបាយការណ៍ ស្វែងយល់ចំណុច

ត្រូវរាយការណ៍ និងយល់ដឹងពីអ្នកអានរបាយការណ៍

- ចំណាយពេលសរសេររបាយការណ៍៖ ត្រូវរៀបចំរបាយការណ៍ឱ្យបានមុនកាលបរិច្ឆេទកំណត់ ២ ឬ៣ថ្ងៃ
- រៀបចំរបាយការណ៍តាមលំដាប់លំដោយ៖
    - ឈ្មោះខណ្ឌរដ្ឋបាលជលផល ទីតាំង ឈ្មោះមន្ត្រីជលផល កាលបរិច្ឆេទរាយការណ៍
    - សកម្មភាព និងលទ្ធផលរបស់ខណ្ឌរដ្ឋបាលជលផល និងសហគមន៍នេសាទ
    - ការប្រែប្រួល និងបញ្ហាប្រឈមដែលទាក់ទងនឹងសកម្មភាព កម្លាំងពលកម្ម និងថវិកាជាដើម។



## សារតារ

គម្រោង "ការគ្រប់គ្រងធនធានទឹកចម្រុះមេគង្គ - ដំណាក់កាលទី៣" ទទួលបានមូលនិធិពីធនាគារពិភពលោក។ គោលបំណងគម្រោង គឺដើម្បីបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងធនធានជលផលប្រកបដោយប្រសិទ្ធភាព នៅភាគឦសាននៃប្រទេសកម្ពុជា។ សមាសភាគទី ១ (ការគ្រប់គ្រងធនធានជលផលនៅភាគឦសាននៃប្រទេសកម្ពុជា) គ្រប់គ្រងដោយរដ្ឋបាលជលផល និងអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប។ គោលបំណងនៃសមាសភាគទី១គឺដើម្បីកែលម្អការគ្រប់គ្រងធនធានជលផលនៅក្នុងតំបន់គោលដៅដែលបានជ្រើសរើសនៅក្នុងខេត្តក្រចេះ និងស្ទឹងត្រែង។

### សៀវភៅមេរៀនចំនួន៥ ស្តីពីសហគ្រប់គ្រងធនធានជលផល

សៀវភៅមេរៀននេះគឺជាផ្នែកមួយនៃសៀវភៅមេរៀនជាស៊េរីចំនួន៥ ស្តីពីសហគ្រប់គ្រងជលផលនៅកម្ពុជា។ សៀវភៅមេរៀនទាំងនេះសម្រាប់ភូមិដែលមានបំណងចង់បង្កើតសហគមន៍នេសាទ សមាជិកសហគមន៍នេសាទ សមាជិកគណៈកម្មការសហគមន៍នេសាទ និងមន្ត្រីខណ្ឌរដ្ឋបាលជលផល។

*សៀវភៅទី១: ការបង្កើតសហគមន៍នេសាទសហគមន៍*
*ក្រុមគោលដៅ: អ្នកភូមិ*
*សៀវភៅទី២: ការពង្រឹងសហគមន៍នេសាទ*
*ក្រុមគោលដៅ: សមាជិកសហគមន៍នេសាទ*
*សៀវភៅទី៣: ការពង្រឹងគណៈកម្មការសហគមន៍នេសាទ*
*ក្រុមគោលដៅ: សមាជិកគណៈកម្មាការសហគមន៍នេសាទ*
***សៀវភៅទី៤: ការពង្រឹងសមត្ថភាពខណ្ឌរដ្ឋបាលជលផល***
*ក្រុមគោលដៅ: បុគ្គលិករដ្ឋបាលជលផល*
*សៀវភៅទី៥: ការកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍*
*ក្រុមគោលដៅ: សមាជិកសហគមន៍នេសាទ*
*ជាពិសេសសមាជិកគណៈកម្មាការសហគមន៍នេសាទ*

រដ្ឋបាលជលផល
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ប្រទេសកម្ពុជា
គេហទំព័រ ifredi-cambodia.org

9 789924 927808